# តើរោគមហារីកកុមារភាពជាអ្វី?

**តើរោគមហារីកជាអ្វី?**
កោសិកាគឺដូចដុំក្មេងលេងសំរាប់សាងសង់សាមញ្ញដែលរួមផ្សំបង្កើតសរីរាង្គនិងជាលិកាទាំងអស់នៅក្នុងដងខ្លួនរបស់យើង។ រោគមហារីកគឺជារោគមួយដែលកោសិកានានានៅក្នុងដងខ្លួនដុះរីកដោយរបៀបមួយដែលពិបាកទប់ទល់។ កោសិការោគមហារីកបំបែកខ្លួនហើយដុះរីកពេលដែលវាមិនគួរដុះរីកហើយនៅរស់យូរជាងពេលដែលវាមិនគួររស់។ កោសិការោគមហារីកអាចកើតជំនួសកោសិកាធម្មតា។ ដុំនៃកោសិការោគមហារីកត្រូវបានហៅថាសាច់ដុះ។ ប្រភេទនីមួយៗនៃរោគមហារីកមានឈ្មោះរបស់វា, ការព្យាបាលរបស់វាហើយនិងឱកាសនៃការជាសះស្បើយរបស់វា។

**តើរោគមហារីកកុមារភាពខុសពីរោគមហារីកមនុស្សពេញវ័យដោយរបៀបណាដែរ?**
អ្វីៗដែលបណ្តាលឲ្យមានរោគមហារីកមនុស្សពេញវ័យ ដូចជាការជក់បារីនិងជាតិគីមីទាំងឡាយមិនមែនជាមូលហេតុជាក់ស្តែងនៃរោគមហារីកក្នុងកុមារទេ។ រោគមហារីករបស់កុមារចេញនៅតាមកន្លែងខុសៗគ្នានៃដងខ្លួនជាងរោគមហារីកមនុស្សពេញវ័យហើយវាមិនសូវកើតមានជាញឹកញាប់ឡើយ។ ប្រភេទនៃរោគមហារីកដែលច្រើនកើតមានជាទូទៅក្នុងមនុស្សពេញវ័យគឺរោគមហារីកស្បែក, ដោះ, ក្រពេញកាម, សួត, និងពោះវៀនធំ។ ក្នុងកុមារ, រោគមហារីកឈាមនិងខួរឆ្អឹង, ជាលិកានៃទឹករងៃ, ខួរក្បាល, ប្រព័ន្ធសរសៃប្រសាទ, សាច់ដុំ, តម្រងមូត្រ, ហើយនិងឆ្អឹងច្រើនកើតមានជាទូទៅ។ រោគមហារីកក្នុងកុមារដូចជាឆាប់មានប្រតិកម្មល្អប្រសើរតបទៅនឹងការព្យាបាលជាងរោគមហារីកក្នុងមនុស្សពេញវ័យហើយការរស់ជាសះស្បើយក្នុងកុមារមានការរស់ខ្ពស់ច្រើនជាងការរស់ក្នុងមនុស្សពេញវ័យ។

## មូលហេតុនៃរោគមហារីកកុមារភាព

មាតាបិតាជាច្រើននាក់ចង់ដឹងថាតើអ្វីទៅដែលបណ្តាលឲ្យមានរោគមហារីករបស់កូនខ្លួន។ គេខ្លាចក្រែងអ្វីដែលគេបានធ្វើ ឬមិនបានធ្វើនោះបានបណ្តាលឲ្យមានរោគនេះ។ តាមយើងដឹង, គ្មានអ្វីសោះឡើយដែលមាតាបិតា ឬកូនបានធ្វើនោះអាចបណ្តាល ឬទប់ស្កាត់រោគមហារីកនេះ។ លោកអ្នកពុំអាចឆ្លងរោគមហារីកពីមនុស្សដទៃទៀតឡើយ។ យើងពុំដឹងនូវមូលហេតុច្បាស់លាស់នៃរោគមហារីកកុមារភាពភាគច្រើននោះទេ ក៏ប៉ុន្តែអ្នកវិទ្យាសាស្ត្រនិយមកំពុងធ្វើការដើម្បីព្យាយាមរកមូលហេតុនេះ។ ចំនួនរោគមហារីកកុមារភាពមានតិចតួចណាស់ដែលតពូជ(បានតពូជពីមាតាបិតាទៅកូន)។ ប្រសិនបើលោកអ្នកមានការរិះគិត ឬ កង្វល់អំពីអ្វីដែលប្រហែលជាអាចបណ្តាលឲ្យមានរោគមហារីករបស់កូនលោកអ្នកនោះ, លោកអ្នកគួរពិភាក្សាជាមួយវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាយិការបស់លោកអ្នក។

**ការប្រកាសមិនទទួលខុសត្រូវ:** សំរាប់ការសិក្សានិងព័ត៌មានតែប៉ុណ្ណោះ។ មាតិកាគឺត្រឹមត្រូវដូចនៅពេលនៃការបោះពុម្ពផ្សាយនេះ, យ៉ាងណាក៏ដោយ, ពេលយូរទៅ ព័ត៌មានប្រហែលជាអាចផ្លាស់ប្តូរ។ សូមស្វែងរកឱវាទជានិច្ចពីក្រុមអ្នកថែរក្សាសុខភាពរបស់លោកអ្នកសំរាប់ឆ្លើយតបទៅនឹងសំនួរវេជ្ជសាស្ត្ររបស់លោកអ្នក។

បានសម្របសម្រួលនិងបានជួយសម្រួលដោយ Paediatric Integrated Cancer Service for the Children's Cancer Centre នៅ The Royal Children's Hospital, Monash Children's – Southern Health and The Peter MacCallum Cancer Centre។ **ខែកញ្ញា ឆ្នាំ 2011**

Paediatric Integrated Cancer Service
A statewide cancer service for children